ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៥២៤ /០១-០៩-២០០៩

សាលដីកា

លេខ : ៦៦(ត) /០២-៩-២០១០

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ:០៦ក្រ ចុះថ្ងៃទី០៨-២-១៩៩៣ បានបើកសវនាការជាសាធារណ:នៅសាលាឧទ្ធរណ៍នាថ្ងៃទី០២-៩-២០១០ដោយមានសមាសភាពដូចតទៅ :

**ក្រុមប្រឹក្សាជំនុំជំរះ**

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍រឿងព្រហ្មទណ្ឌលេខ:៥២៤ ចុះថ្ងៃទី ០១-០៩-២០០៩ រវាង :

-ជនជាប់ចោទឈ្មោះ [redacted] មិនសែ ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីលំនៅមុនចាប់ខ្លួន [redacted] ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) នៅលីវ ។ ឃុំខ្លួនថ្ងៃទី១៣-៤-២០០៩ នៅពន្ធនាគារក្រុងព្រះសីហនុ ។ មេធាវីការពារលោក [redacted] ចន្ថា

ត្រូវចោទពីបទ : ប៉ុនប៉ងរំលោភសេពសន្ថវ: ប្រព្រឹត្តនៅភូមិចំណោតរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីស្ថាន ទម្ងន់ ទោស នៃបទឧក្រិដ្ឋ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លាង ភេទស្រី អាយុ៤៩ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ៤២ ផ្លូវ៩៥

សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។

-បានឃើញសេចក្តីប្តឹងតវ៉ាលេខ៤៨ ចុះថ្ងៃទី ០២-០៧-០៩ របស់ជនជាប់ចោទឈ្មោះ[redacted]មិនសែ ប្តឹងឧទ្ធរណ៍ និងសាលក្រមព្រហ្មទណ្ឌលេខៈ ២២(ខ) ចុះថ្ងៃទី ០២-០៧-២០០៩ របស់សាលាដំបូងខេត្តព្រះសីហនុ ត្រង់ចំណុចទី១ នៃសាលក្រម( ទណ្ឌកម្មធ្ងន់ពេក)។

## រឿងហេតុមានដូចតទៅៈ

តាមកំណត់ហេតុស្តីពីការដាក់ពាក្យបណ្តឹងរបស់ឈ្មោះ[redacted] លាង ប្តឹងពីឈ្មោះ [redacted]មិនសែ ពីបទរំលោភកូនស្រីខ្លួនឈ្មោះ[redacted]លន អាយុ២១ឆ្នាំ (មនុស្ស គរ)។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខៈ២២(ខ) ចុះថ្ងៃទី ០២-៧-២០០៩ របស់សាលាដំបូងខេត្តព្រះសីហនុ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ :

១-ផ្តន្ទាទោសលើឈ្មោះ [redacted]មិនសែ ភេទប្រុស អាយុ២៣ឆ្នាំជាតិខ្មែរ ដាក់ពន្ធនាគារតម្រូវអោយធ្វើការ កំណត់ ១៥ឆ្នាំ (ដប់ប្រាំឆ្នាំ) គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី ១៣-៤-២០០៩។

ពីបទ : ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិចំណោតរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី ១១-៤-០៩ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ។

២-វត្ថុតាងមាន : អាវដៃខ្លី និងខោជើងវែងពណ៌ស លាយខៀវចំនួន១សំរាប់ ខោស្ទីបពណ៌ក្រហមចំនួន០១ និងអាវយឺតដៃខ្លីចំនួន០១ រឹបអូសប្រគល់អោយជនរងគ្រោះ[redacted]លន នៅពេលសាលក្រមចូលស្ថាពរ។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០២-០៧-២០០៩ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ តែកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធិអោយប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញរបាយការណ៍ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ[redacted]មិនសែ (អវត្តមាន)

តំណាងមហាអយ្យការផ្តល់សេចក្តីសន្និដ្ឋានៈ បទល្មើសជាក់ស្តែង បទប៉ុនប៉ងរំលោភលើកុមារី ទណ្ឌកម្មពី ១៥ឆ្នាំឡើងទៅ ហើយការប្តឹងឧទ្ធរណ៍មកគឺសុំបន្ធូរបន្ថយទោស គប្បីសភា..ព្រហ្មទណ្ឌពិចារណា។

មេធាវីផ្តល់សេចក្តីសន្និដ្ឋាន : ចម្លើយកូនក្តីខ្លួនបានបដិសេធ គឺគ្រាន់តែឃើញប្រដាប់ភេទកុមារីនោះ ក៏កើតអារម្មណ៍ ហើយបីកុមារីទៅបត់ជើងអោយឆ្ងាយ។ ក្មេងនេះគឺគរ មានអាយុ២១ឆ្នាំ កូនក្តីខ្លួនពុំទាន់បានរំលោភទេ ក៏ត្រូវឈ្មោះលីវទាញចេញរឿងនេះពុំមានភស្តុតាងអ្វីបន្សល់ទុកដែរ ។ សំណូមពរ សុំកែប្រែពីបទរំលោភមកបៀតបៀនកេរ្តិ៍ខ្មាសវិញ។

ក្រោយពីបានស្តាប់ការអានចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាល្អិតល្អន់ត្រឹមត្រូវតាមច្បាប់ហើយ ។

**យល់ឃើញថា**

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០២-០៧-២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] មិនសែ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ២២"ខ" ចុះថ្ងៃទី០២-០៧-២០០៩ របស់សាលាដំបូងខេត្តព្រះសីហនុ ត្រង់ចំណុចទី ១នៃសេចក្តីសម្រេច ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ អាចទទួលជំនុំជម្រះបាន ។

២-ជនជាប់ចោទបានឆ្លើយសារភាពនៅពេលសវនាការថា ខ្លួនបានសម្រាតខោជនរងគ្រោះបំរុងរួមភេទ ប៉ុន្តែត្រូវបានសាក្សីឈ្មោះ [redacted] លីវ បានមកទាន់ និងឃាត់ខ្លួនបញ្ជូនឱ្យសមត្ថកិច្ចអាចឱ្យតុលាការជឿបានថា ជនជាប់ចោទប្រព្រឹត្តអំពើដូចការចោទប្រកាន់ ដូចដែលបានសំអាងហេតុនៅក្នុងសាលក្រមរបស់សាលាដំបូង ហើយសាលាឧទ្ធរណ៍ឯកភាព ដោយមិនចាំបាច់លើកយកមកសរសេរបញ្ជាក់ឡើងវិញទេ ។

៣-សាលក្រមព្រហ្មទណ្ឌលេខ២២"ខ" ចុះថ្ងៃទី០២-០៧-២០០៩ របស់សាលាដំបូងខេត្តព្រះសីហនុ បានសម្រេចត្រឹមត្រូវហើយ គប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមខាងលើទុកជាបានការ ។

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០២-០៧-២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] មិនសែ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ២២"ខ" ចុះថ្ងៃទី ០២-០៧-២០០៩ របស់សាលាដំបូងខេត្តព្រះសីហនុ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២២"ខ" ចុះថ្ងៃទី ០២-០៧-២០០៩ របស់សាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការ ។

៣-បន្តឃុំខ្លួនជនជាប់ចោទខាងលើតាមនីតិវិធី ។

សាលដីកានេះ ជំនុំជំរះចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជាប់ចោទឈ្មោះ[redacted] មិនសែ ប្រកាសជាសាធារណៈ នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១០ បើកសិទ្ធិប្តឹងទាស់ និងប្តឹងសាទុក្ខក្នុងរយៈពេលដែលច្បាប់កំណត់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្ត សាលដីកានេះ អោយបានសម្រេចបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា : [redacted] | ហត្ថលេខា : [redacted] | ហត្ថលេខា: [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី...13/...ខែ...មករា...ឆ្នាំ2015

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

ក្រឡាបញ្ជី

[redacted]